ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 002/19-09-2007/ECCC/SC

**នៅចំពោះមុខ៖**

ចៅក្រម គង់ ស្រីម ប្រធាន
ចៅក្រម **Chandra Nihal JAYASINGHE**
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម **Agniezska KLONOWIECKAMILART**
ចៅក្រម ម៉ុង មុនីចរិយា
ចៅក្រម **Florence Ndepele Mwachande MUMBA**
ចៅក្រម យ៉ា ណារិន

**កាលបរិច្ឆេទឯកសារ៖** ថ្ងៃទី ៣១ / ខែ តុលា / ឆ្នាំ ២០១៤
**ភាសាដើម៖** ខ្មែរ/អង់គ្លេស
**ចំណាត់ថ្នាក់ឯកសារ៖** សាធារណៈ

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 31-Oct-2014, 15:18
CMS/CFO: Sann Rada

# សេចក្ដីសម្រេចលើសំណើសុំពន្យារពេល និងបន្ថែមចំនួនទំព័រ សម្រាប់សារណាបណ្ដឹងសាទុក្ខ និងសារណាតប

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីជនជាប់ចោទ នួន ជា**
សុន អរុណ
Victor KOPPE

**<u>ជនជាប់ចោទ</u>**

ខៀវ សំផន

នួន ជា

**<u>សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Marie GUIRAUD

**<u>សហមេធាវីជនជាប់ចោទ ខៀវ សំផន</u>**

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

១. **អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" និង "អ.វ.ត.ក") បានទទួល"សំណើលើកទីពីរសុំពន្យារពេល និងបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១" ដែល នួន ជា បានដាក់នៅថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០១៤ ("សំណើសុំរបស់ នួន ជា")[1] និង "*ការស្នើសុំជាបន្ទាន់របស់លោក ខៀវ សំផន សុំពន្យារពេលកំណត់ និងបង្កើនចំនួនទំព័រនៅក្នុងសារណាបណ្តឹងសាទុក្ខ*" ដែលបានដាក់នៅថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១៤ ("សំណើសុំរបស់ ខៀវ សំផន")[2]។ នៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញាបានដាក់សារណាតបរួមទៅនឹងសំណើសុំរបស់ នួន ជា និងសំណើសុំរបស់ ខៀវ សំផន ("សារណាតប")[3] ដែល នួន ជា និង ខៀវ សំផន បានដាក់ចម្លើយតបវិញ នៅថ្ងៃទី ២០ និង ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤[4]។

## សាវតារ

២. នៅថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមរបស់ខ្លួននៅក្នុងសំណុំរឿង ០០២/០១ ("សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង")[5] ដោយបានសម្រេចផ្តន្ទាទោស ខៀវ សំផន និង នួន ជា លើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលក្នុងនោះមានការសម្លាប់រង្គាល(រួមបញ្ចូលទាំងការធ្វើមនុស្សឃាត) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងទៀត (រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ និង ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) និងបានសម្រេចឱ្យជនជាប់ចោទម្នាក់ៗជាប់ពន្ធនាគារ

---

[1] ឯកសារលេខ F6។

[2] ឯកសារលេខ F7។

[3] សារណាតប និងសំណើរបស់សហព្រះរាជអាជ្ញាលើបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១ និងសុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ធ្វើសារណាតប ឯកសារ F7/1 ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤។

[4] ការឆ្លើយតបទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងសំណើសុំបន្ថែមចំនួនទំព័រ និងពេលវេលាបន្ថែមសម្រាប់បណ្តឹងសាទុក្ខ ឯកសារ F7/1/1ចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០១៤("ការឆ្លើយតបរបស់ នួន ជា")។ *ចម្លើយតប និងសារណាតបរបស់ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ទៅនឹង*"ចម្លើយតប និងសំណើរបស់សហព្រះរាជអាជ្ញាលើបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១ និងសុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ធ្វើសារណាតប" ឯកសារ F7/1/2 ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤ ("ការឆ្លើយតបរបស់ ខៀវ សំផន")។

[5] សាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារ E313 ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤។

អស់មួយជីវិត[6]។

៣. នៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤ ទាំង ខៀវ សំផន ទាំង នួន ជា បានស្នើសុំពន្យារពេល និងបន្ថែមចំនួនទំព័រសម្រាប់ការដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណាបណ្តឹងសាទុក្ខរបស់ពួកគេរៀងៗខ្លួន[7]។ ជាពិសេស ជនជាប់ចោទទាំងពីរបានស្នើសុំពន្យារពេលដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរហូតដល់ ៧៤ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង និងបន្ថែមចំនួនទំព័ររហូតដល់ ៥០ ទំព័រ ជាភាសាអង់គ្លេស ឬបារាំង និងសមមូលជាភាសាខ្មែរ[8]។ ជនជាប់ចោទទាំងពីរ បានស្នើសុំស្រដៀងគ្នាផងដែរឲ្យពន្យារពេលដាក់សារណាបណ្តឹងសាទុក្ខរហូតដល់ ១១៧ ថ្ងៃ គិតចាប់ពីថ្ងៃដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងបន្ថែមចំនួនទំព័ររហូតដល់ ១៥០ ទំព័រ ជាភាសាអង់គ្លេស ឬ ភាសាបារាំង និងសមមូលតាមជាភាសាខ្មែរ[9]។

៤. នៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៤ អង្គជំនុំជម្រះតុលាការកំពូលបានយល់ព្រមតាមសំណើសុំពន្យារពេលដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ (ប៉ុន្តែ ច្រានចោលសំណើសុំបន្ថែមចំនួនទំព័រ ដោយអនុញ្ញាតឲ្យដាក់សេចក្តីជូនដំណឹងក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃដាក់សេចក្តីសម្រេចនោះ) ហើយពិចារណាឃើញថា សំណើទាក់ទងនឹងសារណាបណ្តឹងសាទុក្ខនោះ ធ្វើឡើងមុនពេលដែលត្រូវសុំ ដោយពុំទាន់មានក្របខណ្ឌកំណត់ច្បាស់លាស់លើសេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ[10]។

៥. នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ នួន ជា និង ខៀវ សំផន បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដោយលើកឡើងនូវមូលដ្ឋានបណ្តឹង

---

[6] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ទំព័រ ៦២២។

[7] *សំណើបន្ទាន់របស់មេធាវីការពារក្តីលោក ខៀវ សំផន និងមេធាវីការពារក្តី លោក នួន ជា សុំពន្យារពេលកំណត់ និងបង្កើនចំនួនទំព័រនៃបណ្តឹងសាទុក្ខ* ឯកសារ F3 ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤ (“សំណើសុំលើកទីមួយ”)។

[8] សំណើសុំលើកទីមួយ កថាខណ្ឌ ៣០, ៣១។

[9] សំណើសុំលើកទីមួយ កថាខណ្ឌ ៣០, ៣១។

[10] សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំពន្យារពេល និងបន្ថែមចំនួនទំព័រលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណានៃបណ្តឹងសាទុក្ខ ឯកសារ F3/3 ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៤ (“សេចក្តីសម្រេចលើសេចក្តីជូនដំណឹង”)។

សាទុក្ខចំនួន ២២៣ និង ១៤៨ រៀងៗខ្លួន[11]។ សហព្រះរាជអាជ្ញា ក៏បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខនៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ផងដែរ ដោយផ្អែកលើមូលដ្ឋានតែមួយគត់ដោយបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការសម្រេច ដោយពុំបានពិចារណាលើទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម ដែលជាប្រភេទនៃការទទួលខុសត្រូវមួយនោះ[12]។

## សារណា

៦. នៅពេលនេះ នួន ជា ស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូល ច្រានចោលនូវការកម្រិតចំនួនទំព័រណាមួយទាក់ទងនឹងសារណាបណ្តឹងសារទុក្ខរបស់ខ្លួន ដោយបានអះអាងថា ការដាក់កំហិតបែបនេះ ពុំមានចែងនៅក្នុងច្បាប់កម្ពុជា ឬនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ដែលអង្គជំនុំជម្រះតុលាការកំពូលយកមកធ្វើជាមូលដ្ឋាននោះទេ[13]។ ជាជម្រើសមួយទៀត នួន ជា ស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូល ផ្តល់នូវការកម្រិតចំនួនទំព័រត្រឹម៥០០ ទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខរបស់ខ្លួនវិញ[14]។ ចំពោះពេលវេលា នួន ជា ស្នើសុំថា កាលបរិច្ឆេទសម្រាប់ការដាក់សារណាបណ្តឹងសាទុក្ខរបស់គាត់ គួរកំណត់ត្រឹមរយៈពេល ៩០ ថ្ងៃ គិតចាប់ពីថ្ងៃដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់គាត់ ដោយពុំរាប់បញ្ចូលរយៈពេល ដែលត្រូវការសម្រាប់កបកប្រែឯកសារជាភាសាខ្មែរឡើយ (ដូច្នេះ អាចពន្យារកាលបរិច្ឆេទរហូតដល់ពេលពេលការបកប្រែជាភាសាខ្មែរត្រូវបានបញ្ចប់ ឬអនុញ្ញាតឱ្យដាក់សារណាក្នុងរយៈពេល ៩០ ថ្ងៃ ជាភាសាអង់គ្លេសតែមួយគត់ ដោយសំណៅបកប្រែជាភាសាខ្មែរនឹងត្រូវដាក់ជូនតាមក្រោយ ហើយក្នុងករណីនេះ រយៈពេលនៃសារណាតបត្រូវគិតចាប់ពីថ្ងៃដាក់បណ្តឹងសាទុក្ខជាភាសាអង់គ្លេសតែមួយភាសាតែប៉ុណ្ណោះ)[15]។

៧. ខៀវ សំផន ស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលផ្តល់ចំនួនទំព័រ ៣០០ ទំព័រ សម្រាប់សារណា

---

[11] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារ E313/1/1 ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤។ *សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីលោក ខៀវ សំផន ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១* ឯកសារ E313/2/1 ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤។

[12] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាស្តីពីបណ្តឹងសាទុក្ខចំពោះសេចក្តីសម្រេចនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ E313/3/1 ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤។

[13] សំណើសុំរបស់ នួន ជា កថាខណ្ឌ ២(i), ៣-៧, ១៧(ក)(i)។

[14] សំណើសុំរបស់ នួន ជា កថាខណ្ឌ ២(ii), ៨-១២, ១៧(ក)(ii)។

[15] សំណើសុំរបស់ នួន ជា កថាខណ្ឌ ២(iii), ១៣-១៦, ១៧(ខ)។

បណ្តឹងសាទុក្ខរបស់គាត់ជាភាសាបារាំង និងសមមូលជាភាសាខ្មែរ ដោយបានអះអាងថា ក្នុងអំឡុងពេលរៀបចំសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់គាត់ គាត់ឃើញច្បាស់ថា ក្រោយពេលអានលម្អិតលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង គាត់ បានរកឃើញកំហុសច្រើនជាងមុនឆ្ងាយណាស់បើប្រៀបទៅនឹងការអានដោយច្បោលៗពីដំបូងរបស់គាត់ ដូច្នេះ កំហុសទាំងនេះតម្រូវឲ្យមានការពន្យល់លម្អិតច្រើនជាងការលើកឡើងនៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ[16]។ យោងតាមហេតុផលដូចគ្នានេះដែរ ខៀវ សំផន ស្នើសុំថា កាលបរិច្ឆេទសម្រាប់ការដាក់សារណាបណ្តឹងសាទុក្ខរបស់គាត់ គួរត្រូវបានកកំណត់ត្រឹមរយៈពេល ១៧៤ ថ្ងៃ គឺគិតចាប់ពីថ្ងៃដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់គាត់ (*ពោលគឺ* រយៈពេល ៩០ ថ្ងៃ គិតចាប់ពីថ្ងៃដាក់សេចក្តីជូនដំណឹងអំពីបណ្តឹសាទុក្ខ ដើម្បីរៀបចំសារណាបណ្តឹងសាទុក្ខជាភាសាបារាំង បូកនិងពេលវេលាដែលត្រូវបានប៉ាន់ស្មានទុក សម្រាប់ការបកប្រែជាភាសាខ្មែរផងដែរ)[17]។

៨. សហព្រះរាជអាជ្ញាបានដាក់សារណាតបថា ចំនួនទំព័រដែល នួន ជា និង ខៀវ សំផន បានស្នើសុំមានចំនួនច្រើនជ្រុលហួសហេតុ ពុំមានភាពចាំបាច់ ហើយពុំបានធ្វើឡើង ដើម្បីផលប្រយោជន៍យុត្តិធម៌នោះទេ។ ទោះបីជាយ៉ាងនេះក៏ដោយក្តី សហព្រះរាជអាជ្ញាបានបញ្ជាក់ថា ខ្លួនពុំជំទាស់នឹងការបន្ថែមចំនួនទំព័ររហូតដល់ ២០០ ទំព័រ ជាភាសាបារាំង ឬភាសាអង់គ្លេសសម្រាប់ក្រុមមេធាវីការពារក្តីនីមួយៗនោះទេ[18]។ លើសពីនេះទៀត សហព្រះរាជអាជ្ញា ស្នើសុំបន្ថែមចំនួនទំព័រសម្រាប់សារណាតបរបស់ពួកគេ ដោយពុំអាចផ្តល់ចំនួនទំព័រតិចជាងចំនួនទំព័រដែលត្រូវផ្តល់ទៅឲ្យក្រុមមេធាវីការពារក្តី សម្រាប់សារណាបណ្តឹងសាទុក្ខរបស់ពួកគេរួមគ្នានោះឡើយ (មានន័យថា ប្រសិនបើ នួន ជា និង ខៀវ សំផន ត្រូវបានផ្តល់ចំនួនទំព័រ ២០០ ទំព័រ សម្រាប់សារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទរៀងៗខ្លួននោះ សហព្រះរាជអាជ្ញាស្នើសុំ ៤០០ ទំព័រសម្រាប់សារណាតបរួមរបស់ខ្លួន)[19]។

៩. ចំពោះពេលវេលាវិញ សហព្រះរាជអាជ្ញា ពុំបានជំទាស់ទៅនឹងសំណើរបស់ នួន ជា ស្នើសុំរយៈពេល ៩០ ថ្ងៃសម្រាប់ដាក់សារណាតែមួយភាសានោះទេ ប៉ុន្តែ សហព្រះរាជអាជ្ញា បានជំទាស់លើការលើកឡើងថា រយៈពេលសម្រាប់ដាក់សារណាតប គួរតែគិតចាប់ពីថ្ងៃដាក់សារណាបណ្តឹង

---

[16] សំណើសុំរបស់ ខៀវ សំផន កថាខណ្ឌ ៦-១៦, ២៤។ *សូមមើល ផងដែរ* ការឆ្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ១០។

[17] សំណើសុំរបស់ ខៀវ សំផន កថាខណ្ឌ ១៧-២៤។ *សូមមើល ផងដែរ* ការឆ្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ១០។

[18] សារណាតប កថាខណ្ឌ ៨-១៣។ *សូមមើល ផងដែរ ដូចខាងលើ* កថាខណ្ឌ ២៥(ក)។

[19] សារណាតប កថាខណ្ឌ ១៤-១៩, ២៥(ខ)។

សាទុក្ខជាភាសាអង់គ្លេសតែមួយគត់ ហើយសហព្រះរាជអាជ្ញាពិចារណាឃើញថា កាលវិភាគពេលវេលារបស់ ខៀវ សំផន សម្រាប់ការដាក់សារណាជាភាសាបារាំង និងខ្មែរ មានចំនួនច្រើនជ្រុលហួសហេតុ[20]។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលយល់ព្រមផ្តល់រយៈពេល ៩០ ថ្ងៃ គិតចាប់ពីថ្ងៃដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខទៅ នួន ជា និង ខៀវ សំផន សម្រាប់ដាក់សារណាបណ្តឹងសាទុក្ខតែមួយភាសា ដោយសំណៅបកប្រែជាភាសាខ្មែរ នឹងត្រូវដាក់តាមក្រោយ និងត្រូវកំណត់កាលបរិច្ឆេទនៃការដាក់សារណាបណ្តឹងសាទុក្ខឱ្យបានដូចគ្នាសម្រាប់សហព្រះរាជអាជ្ញា ហើយត្រូវផ្តល់រយៈពេល ៩០ ថ្ងៃ ដល់សហព្រះរាជអាជ្ញា ដោយគិតចាប់ពីថ្ងៃដាក់សារណាបណ្តឹងសាទុក្ខជាភាសាខ្មែរ ដើម្បីដាក់សារណាតបរបស់ខ្លួនតែមួយភាសា ដោយសំណៅបកប្រែជាភាសាខ្មែរនឹងត្រូវដាក់តាមក្រោយ[21]។

១០. នួន ជា និង ខៀវ សំផន បានអះអាងនៅក្នុងការឆ្លើយតបរបស់ពួកគេថា សំណើសុំរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងសារណាតបរបស់ពួកគាត់ មានលក្ខណៈហួសហេតុ និងគ្មានយុត្តិកម្ម។ អាស្រ័យហេតុនេះ នួន ជា និង ខៀវ សំផន បានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលច្រានចោលសំណើសុំទាំងនេះ[22]។

## ច្បាប់ជាធរមាន

១១. វិធាន ១០៥(៣) នៃវិធានផ្ទៃក្នុង[23] ចែងថា “[ភាគី] ដែលមានបំណងប្តឹងសាទុក្ខចំពោះសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខដោយបញ្ជាក់ពីមូលដ្ឋាននៃបណ្តឹងសាទុក្ខនោះ” ហើយ “បន្ទាប់មក ម្ចាស់បណ្តឹងសាទុក្ខត្រូវដាក់សារណាបណ្តឹងសាទុក្ខដោយបញ្ជាក់ពីទឡ្ហីករណ៍ និងឯកសារសំអាងផ្លូវច្បាប់ដែលគាំទ្រមូលដ្ឋាននីមួយៗ”។ វិធាន ១០៧(៤) នៃវិធានផ្ទៃក្នុងចែងបញ្ជាក់ច្បាស់ថា សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខត្រូវដាក់ក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ហើយសារណាបណ្តឹងសាទុក្ខត្រូវដាក់ក្នុងរយៈពេល ៦០ ថ្ងៃ គិតចាប់ពីថ្ងៃដាក់សេចក្តីជូនដំណឹងអំពី

[20] សារណាតប កថាខណ្ឌ ២១។

[21] សារណាតប កថាខណ្ឌ ២២-២៥។

[22] សារណាតបរបស់ នួន ជា កថាខណ្ឌ ១-៧។ ការឆ្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ១-១០។

[23] វិធានផ្ទៃក្នុងនៃ អ.វ.ត.ក វិសោធនកម្មលើកទី ៨ ចុះថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១១ (“វិធានផ្ទៃក្នុង”)។

បណ្តឹងសាទុក្ខ។ មាត្រា ៨.៣ និងមាត្រា ៨.៤ នៃសេចក្តីណែនាំអនុវត្ត[24] ចែងថា ចម្លើយតបទាំងឡាយទៅនឹងពាក្យសុំ ឬសេចក្តីសន្និដ្ឋានណាមួយត្រូវដាក់ក្នុងរយៈពេល ១០ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹង ហើយការឆ្លើយតបទៅនឹងចម្លើយតបត្រូវដាក់ក្នុងរយៈពេល ៥ ថ្ងៃ ហើយការឆ្លើយតបទាំងនេះ នឹងអនុញ្ញាតឱ្យធ្វើឡើងក្នុងករណីដែលពុំមានសវនាការផ្តល់ទឡ្ហីករណ៍ផ្ទាល់មាត់លើពាក្យសុំ ឬសេចក្តីសន្និដ្ឋានតែប៉ុណ្ណោះ។ អនុលោមតាមមាត្រា៥.២ នៃសេចក្តីណែនាំអនុវត្ត ចំនួនទំព័រនៃឯកសារដែលបានដាក់ជូនអង្គជំនុំជម្រះតុលាការកំពូល ពុំអាចលើសពីចំនួន ៣០ ទំព័រជាភាសាអង់គ្លេស ឬ បារាំង ឬ ៦០ ទំព័រជាភាសាខ្មែរនោះទេ។

១២. វិធាន ៣៩(២) នៃវិធានផ្ទៃក្នុងចែងប្រមើលមើលជាមុនថា លើកលែងតែមានចែងផ្សេងពីនេះនៅក្នុងវិធានផ្ទៃក្នុង ចៅក្រមអាចកំណត់ពេលវេលាសម្រាប់ដាក់សារណា សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងឯកសារពាក់ព័ន្ធនឹងសំណើសុំណាមួយ ឬបណ្តឹងឧទ្ធរណ៍ ឬ បណ្តឹងសាទុក្ខ។ វិធាន ៣៩(៤) នៃវិធានផ្ទៃក្នុងក៏បានផ្តល់អំណាចឱ្យចៅក្រម “ពន្យារពេលវេលាកំណត់ដែលខ្លួនបានកំណត់” ឬ “ទទួលស្គាល់ថា មានសុពលភាពចំពោះកិច្ចទាំងឡាយណាដែលបានធ្វើក្រោយពីពេលកំណត់ដែលមានចែងនៅក្នុង [វិធានផ្ទៃក្នុង] នេះត្រូវបានផុតរលត់ ប្រសិនបើខ្លួនយល់ឃើញថាត្រឹមត្រូវសមហេតុផល”[25]។ មាត្រា ៥.៤ នៃសេចក្តីណែនាំអនុវត្តចែងថា អង្គជំនុំជម្រះពាក់ព័ន្ធ តាមសំណើសុំរបស់ភាគី អាចបន្ថែមចំនួនទំព័រជាធរមាន ក្នុងករណីលើកលែងនានាបាន។

## ការពិភាក្សា

១៣. អង្គជំនុំជម្រះតុលាការកំពូលសូមរំឮកពីសេចក្តីសម្រេចកន្លងមករបស់ខ្លួនថា “ទាក់ទងនឹង [...] សារណាបណ្តឹងសាទុក្ខ និងសារណាតប អង្គជំនុំជម្រះតុលាការកំពូល ពិចារណាអំពីភាពជាក់ស្តែងឃើញថា ការពន្យារពេល ចាំបាច់ត្រូវបានអនុញ្ញាត ដោយសំអាងលើទំហំ និងភាពស្មុគស្មាញនៃសំណុំរឿង និងសាលក្រម”[26]។ ក្នុងពេលនេះ ការជូនដំណឹងពីបណ្តឹងសាទុក្ខ ត្រូវបានដាក់ ហើយលក្ខខណ្ឌដែលចាំបាច់ក្នុងការវាយតម្លៃទៅលើការបង្កើនចំនួន និងពេលវេលាជាចាំបាច់ មាន

---

[24] សេចក្តីណែនាំអនុវត្តស្តីអំពីការដាក់ឯកសារនៅ អ.វ.ត.ក វិសោធនកម្មលើកទី ៨ ចុះថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១២ (“សេចក្តីណែនាំអនុវត្ត”)។

[25] *សូមមើល ផងដែរ* មាត្រា ៨.១ នៃសេចក្តីណែនាំអនុវត្ត។

[26] សេចក្តីសម្រេចលើការជូនដំណឹង, កថាខណ្ឌ ១០។

ភាពច្បាស់លាស់ជាងមុន ហើយអាចបង្ហាញឱ្យឃើញច្បាស់ថា បណ្តឹងសាទុក្ខរបស់ នួន ជា និង ខៀវ សំផន នឹងមានលក្ខណៈទូលំទូលាយ ដែលតម្រូវឱ្យមានពេលវេលា និងចំនួនទំព័រគ្រប់គ្រាន់សម្រាប់ការលើកឡើងដែលប្រកបដោយអត្ថន័យ។

១៤. ដូច្នេះបញ្ហានេះ ពុំអាចកើតមានឡើង ចំពោះការជូនដំណឹងពីបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ដែលមានចំនួនប្រាំទំព័រឡើយ ដែលការជូនដំណឹងនេះ គឺទាក់ទងតែទៅនឹងសេចក្តីសម្រេចតែមួយ និងបញ្ហាតែមួយប៉ុណ្ណោះ ហើយមានអំណះអំណាងរួចជាស្រេចហើយ។ សំអាងហេតុតែមួយដែលពួកគេបានផ្តល់ ដើម្បីគាំទ្រដល់សំណើសុំ កំណត់កាលបរិច្ឆេទសម្រាប់ការដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន ដែលត្រូវតែដូចគ្នាទៅនឹងសារណារបស់ នួន ជា និង ខៀវ សំផន នោះ គឺគ្រាន់តែលើកឡើងអំពី"ភាពងាយស្រួល និងភាពដូចគ្នា នៅក្នុងការកំណត់កាលបរិច្ឆេទ សម្រាប់ការធ្វើសារណា ឬសវនាការលើបណ្តឹងសាទុក្ខក្រោយៗតែប៉ុណ្ណោះ"[27]។ អង្គជំនុំជម្រះតុលាការកំពូលសូមបញ្ជាក់ឡើងវិញថា "ការពន្យារពេល ដែលស្នើឡើងសម្រាប់ដាក់សារណាបណ្តឹងសាទុក្ខ ត្រូវស្របគ្នាទៅនឹងទំហំនៃបណ្តឹងសាទុក្ខរបស់ម្ចាស់បណ្តឹងសាទុក្ខ ហើយពុំគ្រាន់តែធ្វើការប្រដូចទៅនឹងការពន្យារពេលដែលបានស្នើឡើងដោយម្ចាស់បណ្តឹងសាទុក្ខដទៃទៀតនោះឡើយ"[28]។ ហេតុដូច្នេះ សំណើរបស់សហព្រះរាជអាជ្ញា សុំពន្យារពេលវេលាដាក់សារណាបណ្តឹងសាទុក្ខត្រូវបានបដិសេធទាំងស្រុងតែម្តង។

១៥. ក្នុងលក្ខណៈប្រហែលគ្នានេះ អង្គជំនុំជម្រះតុលាការកំពូល បដិសេធលើការអះអាងរបស់ នួន ជា ដែលថា មិនត្រូវមានការកម្រិតទៅលើចំនួនទំព័រ ទាំងនៅក្នុងបរិបទកម្ពុជា ឬបរិបទនៃប្រព័ន្ធច្បាប់ស៊ីវិល ឬក៏នៅក្នុងសំណុំរឿងជាក់លាក់មួយនេះ ចោល[29]។ ការដាក់កំណត់លើចំនួនទំព័រនៃសារណា មិនមែនដោយសារតែការពិចារណាទៅលើទស្សនវិជ្ជាផ្លូវច្បាប់នោះឡើយ ប៉ុន្តែ លើប្រសិទ្ធភាពរបស់តុលាការ។ តាមពិតទៅ សឹងតែគ្រប់តុលាការពិសេស និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ឬដែលមានលក្ខណៈជាអន្តរជាតិសម័យបច្ចុប្បន្នទាំងអស់ ដែលរឿងក្តីនៅទីនោះ មានលក្ខណៈធំ និងស្មុគស្មាញ ដូចសំណុំរឿងនេះ គឺសុទ្ធតែមានការកំណត់ទៅលើចំនួនទំព័រយ៉ាងច្បាស់

---

[27] សារណាតប, កថាខណ្ឌ ២២។

[28] សេចក្តីសម្រេចលើការជូនដំណឹង, កថាខណ្ឌ ១០។

[29] *សូមមើលផ្នែកខាងលើ* កថាខណ្ឌ ៦។

ណាស់[30]។ លើសពីនេះទៀត តុលាការទាំងអស់នេះភាគច្រើនបានបញ្ជាក់ថា នៅក្នុងរឿងក្ដីដែលមានជនជាប់ចោទច្រើន ម្ចាស់បណ្ដឹងសាទុក្ខនីមួយៗ ត្រូវបានអនុញ្ញាតឲ្យដាក់បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម និងសារណាតប ត្រឹមតែ ១០០ ទំព័រប៉ុណ្ណោះ លើកលែងតែរដ្ឋអាជ្ញាដែលត្រូវបានអនុញ្ញាតឲ្យដាក់បណ្ដឹងសាទុក្ខ និងសារណាតបទៅនឹងម្ចាស់បណ្ដឹងសាទុក្ខទីមួយចំនួន ១០០ ទំព័រ ហើយបន្ថែមប្រហែលមួយភាគបីនៃចំនួនទំព័រ តបទៅនឹងម្ចាស់បណ្ដឹងសាទុក្ខផ្សេងទៀត ដោយមិនគិតថាតើ រដ្ឋអាជ្ញា ដាក់សារណារួមគ្នា ឬដាច់ពីគ្នានោះទេ[31]។ ក្នុងបរិបទបច្ចុប្បន្ននេះ នួន ជា និង ខៀវ សំផន នឹងអាចទទួលបានចំនួន ១០០ ទំព័រ ម្នាក់សម្រាប់បណ្ដឹងសាទុក្ខ ហើយសហព្រះរាជអាជ្ញា នឹងអាចទទួលបាន ១៣៣ ទំព័រ សម្រាប់ដាក់សារណាតប ដោយ

---

[30] នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ សូមមើលបទបញ្ជារបស់តុលាការ, ICC-BD/01-03-11, ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១១, បទបញ្ជាលេខ ៥៨(៨) ("ឯកសារសម្រាប់គាំទ្របណ្ដឹងសាទុក្ខ មិនត្រូវលើសពី១០០ទំព័រឡើយ")។ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា ("តុលាការ ICTR"), សូមមើលសេចក្ដីណែនាំអនុវត្ត អំពីចំនួនទំព័រសារណា និងញត្តិ, ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៦ ("សេចក្ដីណែនាំអនុវត្តរបស់តុលាការ ICTR", ផ្នែក(ខ) អំពីទំហំអក្សរ ("ចំពោះទំព័រធម្មតា មិនគួរមានត្រឹម ៣០០ ពាក្យ ឬតិចជាងនេះ") ហើយមាត្រា ១ ("(ក) សារណារបស់ម្ចាស់ បណ្ដឹងសាទុក្ខចំពោះសាលក្រមស្ដាពររបស់អង្គជំនុំជម្រះសាលាដំបូង មិនត្រូវលើសពី ៣០ ០០០ ពាក្យឡើយ (មិនត្រូវលើស ១២ ០០០ ចំពោះបណ្ដឹងសាទុក្ខ តែចំពោះការផ្ដន្ទាទោស)៖ ក្នុងករណីដែល រដ្ឋអាជ្ញាជាម្ចាស់បណ្ដឹងសាទុក្ខ ហើយដាក់សារណាដាច់ពីគ្នា ចំពោះភាគីចុងចម្លើយសាទុក្ខនីមួយៗ ឬសារណារួមគ្នាតែមួយ ចំនួនពាក្យសរុបមិនឲ្យលើស ៣០ ០០០ពាក្យឡើយ ទាក់ទងទៅនឹងចុងចម្លើយសាទុក្ខមួយ ហើយនឹងមិនលើស ១០ ០០០ ពាក្យឡើយសម្រាប់ចុងចម្លើយសាទុក្ខបន្ថែមម្នាក់ៗទៀត។ [...] (ខ) ចម្លើយតបរបស់ចុងចម្លើយសាទុក្ខចំពោះបណ្ដឹងសាទុក្ខ លើសាលក្រមស្ដាពរ របស់អង្គជំនុំជម្រះសាលាដំបូង នឹងមិនត្រូវលើសពី ៣០ ០០០ ពាក្យឡើយ (មិនត្រូវលើសពី ១២ ០០០ ប្រសិនបើបណ្ដឹងសាទុក្ខ តែចំពោះការផ្ដន្ទាទោស) អាស្រ័យទៅលើបទប្បញ្ញត្តិនៅ (ក)(១) ដោយអនុវត្តគោលការណ៍ ប្រសិនបើមានការចាំបាច់ ចំពោះសារណាណាដែលឆ្លើយតបចំពោះ សារណាដែលដាក់ដោយរដ្ឋអាជ្ញា")។ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("តុលាការ ICTY") សូមមើលសេចក្ដីណែនាំអនុវត្តស្ដីពីចំនួនទំព័រសារណា និងញត្តិ, IT/184 Rev. 2, ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៥ ("សេចក្ដីណែនាំអនុវត្តរបស់តុលាការ ICTY") ផ្នែក (ខ) ស្ដីពីទំហំអក្សរ និងមាត្រា ១ (ដូចក្នុងសេចក្ដីណែនាំអនុវត្តរបស់តុលាការ ICTR បេះបិទ)។ នៅតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ("តុលាការ SCSL") សូមមើលសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅចំពោះមុខតុលាការ SCSL, ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៥, មាត្រា ៦(ង)(១) ("សារណារបស់បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម ឬការផ្ដន្ទាទោស មិនត្រូវលើសពី ១០០ទំព័រ ឬ ៣០ ០០០ពាក្យ ដោយគិតលើមួយណាដែលច្រើនជាង")។ នៅតុលាការពិសេសសម្រាប់ប្រទេសលីបង់ ("តុលាការ STL") សូមមើលសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅចំពោះមុខតុលាការ STL, STL/PD/2010/01/Rev.2, ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៣, មាត្រា ៥(១)(ជ) ("សារណារបស់ម្ចាស់បណ្ដឹងសាទុក្ខ មិនត្រូវលើសពី ៣០ ០០០ ពាក្យ (គិតត្រឹម ១២ ០០០ពាក្យ នៅពេលដែលបណ្ដឹងសាទុក្ខ កម្រិតត្រឹមការផ្ដន្ទាទោស ឬនៅពេលដែលបណ្ដឹងសាទុក្ខធ្វើឡើងប្រឆាំងនឹងសាលក្រម តាមវិធាន ៦០ស្ទួន, វិធាន ១៣៥ ឬវិធាន ១៥២)")។

[31] មាត្រា ១(ក)(១) និង១(ខ) នៃសេចក្ដីណែនាំអនុវត្តរបស់តុលាការ ICTR និង ICTY។

ត្រូវបែងចែក១០០ ទំព័រទៅឱ្យ នួន ជា ឬក៏ ខៀវ សំផន ហើយ ៣៣ ទំព័រទៀត សម្រាប់អ្នកណាម្នាក់ទៀត ឬក៏ដាក់សារណាតបរួមតែមួយដែលមានចំនួន ១៣៣ ទំព័រ។

១៦. អង្គជំនុំជម្រះតុលាការកំពូលរំឮកថា កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខនៅចំពោះមុខ អ.វ.ត.ក គឺខុសប្លែកពីកិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ ឬតុលាការដទៃដែលមានលក្ខណៈអន្តរជាតិ នៅក្នុងការកម្រិតយុត្តាធិការបណ្តឹងសាទុក្ខបន្ទាន់បង្គំ ទៅលើបញ្ហាដែលបានកំណត់ជាក់លាក់ចំនួនបួន និងក្នុងការរក្សាទុកនូវសិទ្ធិក្នុងការការពិនិត្យលើសេចក្តីសម្រេចផ្សេងៗរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានធ្វើឡើងនៅក្នុងកិច្ចដំណើរការនីតិវិធី នៅដំណាក់កាលមួយដែលមានការប្តឹងសាទុក្ខលើអង្គសេចក្តីនៃសាលក្រម[32]។ នួន ជា បានបង្ហាញថា ក្រៅពីមូលដ្ឋានដែលបានបញ្ជាក់ទាំង ២២៣ បណ្តឹងសាទុក្ខរបស់គាត់ នឹងរួមបញ្ចូលនូវសេចក្តីសម្រេចផ្សេងៗគ្នា របស់អង្គជំនុំជម្រះសាលាដំបូងលើស្រុកចំនួន ១៦ ទៀត "ដែលភាគច្រើនពាក់ព័ន្ធនឹងសេចក្តីសម្រេចដោយផ្ទាល់មាត់ជាច្រើន នៅក្នុងពេលសវនាការ"[33]។ ខៀវ សំផនបានបង្ហាញយ៉ាងត្រឹមត្រូវថា ប្រសិនបើខ្លួនអាចប្តឹងសាទុក្ខទៅលើសេចក្តីសម្រេចទាំងអស់នេះ នៅក្នុងអំឡុងពេលសវនាការ ខ្លួននឹងទទួលបានផលប្រយោជន៍ពីការផ្តល់ឲ្យចំនួន ៣០ ទំព័រ សម្រាប់បណ្តឹងសាទុក្ខបន្ទាន់បង្គំនីមួយៗ[34]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលបានសង្កត់ធ្ងន់ថា បណ្តឹងសាទុក្ខលើសេចក្តីសម្រេចនេះ (ជាឧទាហរណ៍ បណ្តឹងសាទុក្ខ ដែលត្រូវបានអនុញ្ញាតឱ្យប្តឹងក្នុងពេលដំណាលគ្នាជាមួយនឹងសាលក្រមលើអង្គសេចក្តី) ត្រូវបង្ហាញពី*ការប៉ះពាល់*ជានិរន្តរបស់ម្ចាស់បណ្តឹងសាទុក្ខ។ ដូច្នេះ បណ្តឹងសាទុក្ខនៃសេចក្តីសម្រេចនេះ ត្រូវតែជាប់ទាក់ទងទៅនឹងទឡ្ហីករណ៍មួយ ឬច្រើននៃបណ្តឹងសាទុក្ខលើសាលក្រម។

១៧. ហេតុដូច្នេះ ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា ម្ចាស់បណ្តឹងសាទុក្ខទាំងអស់ នឹងប្រឹងប្រែងបរិយាយដោយសង្ខេបហើយច្បាស់ៗតាមដែលអាចធ្វើទៅបាន និងមិននិយាយលើសពីអ្វីដែលជាការចាំបាច់ ដើម្បីបង្ហាញរឿងក្តីរបស់ពួកគេម្នាក់ៗក៏ដោយ[35] ក៏អង្គជំនុំជម្រះពិចារណាឃើញថា ការដាក់កំណត់ទៅលើចំនួនទំព័រ គឺជាការចាំបាច់ ហើយយល់ឃើញថា ការម្រិត២១០ទំព័រ សម្រាប់សារណាបណ្តឹងសាទុក្ខនីមួយៗរបស់ នួន ជា និង ខៀវ សំផន និងការកម្រិតចំនួន

---

[32] សូមមើល វិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង។

[33] សំណើរបស់ នួន ជា, កថាខណ្ឌ ៨។

[34] សំណើរបស់ ខៀវ សំផន, កថាខណ្ឌ ១៥។

[35] សូមមើល សំណើរបស់ នួន ជា, កថាខណ្ឌ ៧ និងសំណើរបស់ ខៀវ សំផន, កថាខណ្ឌ ១០។

២៨០ទំព័រ សម្រាប់សារណាតបរួមរបស់សហព្រះរាជអាជ្ញា គឺជាការសមស្របក្នុងកាលៈទេសៈបច្ចុប្បន្ននេះ។

១៨. ពាក់ព័ន្ធទៅនឹងពេលវេលា អង្គជំនុំជម្រះតុលាការកំពូលកត់សំគាល់ថា ម្ចាស់បណ្ដឹងសាទុក្ខនៅតុលាការមិនអចិន្ត្រៃយ៍ តាមផ្លូវច្បាប់ ត្រូវបានផ្ដល់ឱ្យរយៈពេល ៧៥ ថ្ងៃ គិតចាប់ពីថ្ងៃដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ដើម្បីដាក់សារណាបណ្ដឹងសាទុក្ខរបស់ពួកគេ[36]។ ទោះជាយ៉ាងនេះក្ដី ដោយពិចារណាលើកាលៈទេសៈពិសេស ដែលថា ការដាក់សារណានៅចំពោះមុខ អ.វ.ត.ក ត្រូវធ្វើឡើងជាពីរភាសា តាមវិធានទូទៅនោះ[37] អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា រយៈពេល ៦០ ថ្ងៃ ដែលមានកំណត់នៅក្នុងវិធាន ១០៧(៤) នៃវិធានផ្ទៃក្នុងនោះ មិនគ្រប់គ្រាន់ឡើយសម្រាប់ នួន ជា និង ខៀវ សំផន ក្នុងការប្ដឹងសាទុក្ខប្រកបដោយអត្ថន័យប្រឆាំងនឹងសាលក្រមដែលមានទំហំធំ និងមានភាពស្មុគស្មាញដូចសំណុំរឿងបច្ចុប្បន្ននេះ។ សហព្រះរាជអាជ្ញាយល់ស្របថា នួន ជា និង ខៀវ សំផន ត្រូវការពេលវេលា ៩០ ថ្ងៃ ដើម្បីរៀបចំសារណាបណ្ដឹងសាទុក្ខរបស់ពួកគេតែមួយភាសាប៉ុណ្ណោះ។ យោងតាមសំអាងហេតុទាំងនេះ រួមជាមួយនឹងសំអាងហេតុនានាដូចបានបង្ហាញពីខាងលើ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការបន្ថែមពេលវេលាគឺជាការចាំបាច់ សម្រាប់ក្រុមមេធាវីការពារក្ដី និងថា រយៈពេល ៣០ ថ្ងៃបន្ថែមចំពោះ នួន ជា និង ខៀវ សំផន ក្នុងការដាក់សារណាបណ្ដឹងសាទុក្ខរបស់ពួកគេ គឺមានលក្ខណៈសមហេតុផលសម្រាប់កាលៈទេសៈនេះ។

១៩. អង្គជំនុំជម្រះតុលាការកំពូលក៏ពិចារណាឃើញផងដែរថា សំណើសុំដាក់សារណាតែមួយភាសាមានភាពសមហេតុផល ដោយសារតែមានការបង្ហាញនូវការលំបាកថ្មីៗ ដែលនៅតែមាន នៅក្នុងអង្គភាពបកប្រែភាសា[38]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ក្នុងកាលៈទេសៈបែប

---

[36] សូមមើល វិធាន ១១១(ក) នៃវិធានស្ដីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTR និងតុលាការ ICTY ("សារណារបស់ម្ចាស់បណ្ដឹងសាទុក្ខ ដែលលើកឡើងអំពីទឡ្ហីករណ៍ និងឯកសារគតិយុត្តិ ត្រូវដាក់ក្នុងរយៈពេលចិតសិបប្រាំថ្ងៃ បន្ទាប់ពីដាក់ការជូនដំណឹងស្ដីពីបណ្ដឹងសាទុក្ខ អនុលោមតាមវិធាន ១០៨")។

[37] សូមមើល មាត្រា ៧.១ នៃសេចក្ដីណែនាំអនុវត្ត ("គ្រប់ឯកសារទាំងអស់ត្រូវដាក់ជាភាសាខ្មែររួមជាមួយអង់គ្លេស និង/ឬបារាំង")។

[38] សូមមើល ជាឧទាហរណ៍ អនុស្សរណៈរបស់ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា "សំណើរបស់មេធាវីការពារក្ដី ខៀវ សំផន សុំឱ្យអង្គជំនុំជម្រះសាលាដំបូង បង្គាប់ដល់ការិយាល័យរដ្ឋបាល ឱ្យពង្រឹងសមត្ថភាពរបស់អង្គភាពបកប្រែភាសាជាបន្ទាន់", ឯកសារ E317/1,ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤។

នេះ តម្រូវឱ្យមានការលើកលែងដូចដែលមានចែងក្នុងមាត្រា ៧(២) នៃសេចក្តីណែនាំអនុវត្ត ដែលអនុញ្ញាតឱ្យភាគី "ដាក់ឯកសារជាភាសាបារាំង ឬភាសាអង់គ្លេស ជាបឋមបាន ប៉ុន្តែបន្ទាប់មកភាគីត្រូវដាក់ឯកសារជាភាសាខ្មែរដែលបានបកប្រែរួច ឱ្យបានឆាប់រហ័សបំផុត"។ ហេតុដូច្នេះ នួន ជា និង ខៀវ សំផន អាចដាក់សារណាបណ្តឹងសាទុក្ខរបស់ពួកគេ ក្នុងរយៈពេល ៩០ ថ្ងៃយ៉ាងយូរបំផុត បន្ទាប់ពីការជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ពួកគេ ជាភាសាបារាំង ឬភាសាអង់គ្លេស ហើយ ឯកសារជាភាសាខ្មែរ នឹងត្រូវដាក់ពេលក្រោយឱ្យបានឆាប់រហ័សបំផុតតាមដែលអាចធ្វើបាន។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលរំពឹងថា នួន ជា និង ខៀវ សំផន នឹងប្រើប្រាស់ធនធានទាក់ទងនឹងភាសាខ្មែរ ដែលមាននៅក្នុងក្រុមរបស់ខ្លួន បានល្អប្រសើរបំផុត ក្នុងការបំពេញការងារឱ្យបានស្របគ្នាជាមួយនឹងអង្គភាពបកប្រែភាសា ក្នុងគោលបំណងពន្លឿននៃការបកប្រែភាសាខ្មែរលើសារណានៃបណ្តឹងសាទុក្ខរៀងៗខ្លួន។

២០. ពាក់ព័ន្ធសារណាតបរបស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា ការកម្រិតត្រឹម ១០ ថ្ងៃ ដូចមានចែងក្នុងមាត្រា ៨.៣ នៃសេចក្តីណែនាំអនុវត្ត មិនគ្រប់គ្រាន់ឡើយនៅក្នុងកាលៈទេសៈបច្ចុប្បន្ននេះ។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា សំណើរបស់សហព្រះរាជអាជ្ញាដែលសុំពេលវេលាស្មើគ្នា (ឧទាហរណ៍ ៩០ ថ្ងៃ) ដោយគិតពីថ្ងៃដាក់ឯកសារបកប្រែជាភាសាខ្មែរនោះ មានលក្ខណៈច្រើនហួសហេតុ និងមិនចាំបាច់។ អង្គជំនុំជម្រះតុលាការកំពូលកត់សំគាល់ថា ជាទូទៅតុលាការមិនអចិន្ត្រៃយ៍តែងផ្តល់ពេលវេលាឱ្យប្រហែលពាក់កណ្តាល ចំពោះសារណាតប ធៀបទៅនឹងពេលវេលាដែលផ្តល់ឱ្យសម្រាប់សារណាបណ្តឹងសាទុក្ខ[39] ហើយអង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា សហព្រះរាជអាជ្ញានឹងអាចធ្វើការពិភាក្សា ព្រមទាំងដំណើរការការងារបឋមបានយ៉ាងច្រើននៅក្នុងការរៀបចំសារណាតបរបស់ខ្លួន នៅពេលបានទទួលសារណាបណ្តឹងសាទុក្ខជាភាសាអង់គ្លេស ឬភាសាបារាំង។

២១. ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះតុលាការកំពូលសម្រេចបដិសេធការលើកឡើងរបស់ នួន ជា ដែលថា ការកម្រិតពេលវេលាសម្រាប់សារណាតប គួរចាប់ផ្តើមគិតចាប់ពីថ្ងៃដាក់សារណាតែមួយភាសាប៉ុណ្ណោះ។ មាត្រា ៧.១ នៃសេចក្តីណែនាំអនុវត្តបានចែងថា "គ្រប់ឯកសារទាំងអស់ត្រូវដាក់

---

[39] សូមមើល វិធាន ១១២(ក) នៃវិធានស្តីពីនីតិវិធី និងភស្តុតាង របស់តុលាការ ICTR និងតុលាការ ICTY ("សារណារបស់អ្នកផ្តល់ចម្លើយតប អំពីទឡ្ហីករណ៍ និងឯកសារគតិយុត្តិ ត្រូវដាក់ក្នុងរយៈពេល សែសិបថ្ងៃ បន្ទាប់ពីការដាក់សារណារបស់ម្ចាស់បណ្តឹងសាទុក្ខ")។

ជាភាសាខ្មែររួមជាមួយអង់គ្លេស និង/ឬបារាំង"។ អង្គជំនុំជម្រះតុលាការកំពូលសូមរំឭកថា ភាគីទាំងអស់ត្រូវប្រឹងប្រែងគ្រប់ពេល ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវជាទូទៅនៃការដាក់ឯកសារទាំងពីរភាសាក្នុងពេលជាមួយគ្នា នៅចំពោះមុខ អ.វ.ត.ក ហើយមិនត្រូវមើលរំលងសារៈសំខាន់នៃការដាក់ឯកសារជាភាសាខ្មែរនោះឡើយ ជាពិសេសចំពោះមាត្រា ៨.៥ នៃសេចក្តីណែនាំអនុវត្តដែលចែងថា "ពេលវេលាកំណត់ត្រូវរាប់មួយថ្ងៃបន្ទាប់ពីថ្ងៃនៃការជូនដំណឹងពីឯកសារជាភាសាខ្មែរ និងភាសាផ្លូវការមួយផ្សេងទៀតរបស់ អ.វ.ត.ក"[40]។ ហេតុដូច្នេះ ឯកសារជាភាសាខ្មែរដែលត្រូវដាក់នៅចំពោះមុខ អ.វ.ត.ក គឺជាផ្នែកដ៏សំខាន់នៃកិច្ចដំណើរការនីតិវិធីនៅតុលាការនេះ ព្រោះថា ផ្នែកជាតិ និងផ្នែកអន្តរជាតិនៃស្ថាប័ននីមួយៗ ត្រូវតែបំពេញការងារជាមួយគ្នា ដើម្បីសម្រេចបានលទ្ធផលការងារផ្សេងៗ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ជាការសមស្របដែលអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាដាក់ចម្លើយតបរួមរបស់ពួកគេ ក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីទទួលបានការជូនដំណឹងពីសារណាបណ្តឹងសារទុក្ខរបស់ នួន ជា និង ខៀវ សំផន ជាភាសាខ្មែរ ដោយគិតពីសារណាណាមួយដែលត្រូវបានជូនដំណឹងក្រោយគេ។

២២. ពាក់ព័ន្ធនឹងលទ្ធភាពនៃការឆ្លើយតប អង្គជំនុំជម្រះតុលាការកំពូលសូមរំឭកថា មាត្រា ៨.៤ នៃសេចក្តីណែនាំអនុវត្ត ចែងថា "ការឆ្លើយតបទៅនឹងចម្លើយតប ត្រូវបានអនុញ្ញាតតែក្នុងករណីដែលមិនមានការស្នើសុំឱ្យមានការដេញដោលដោយផ្ទាល់មាត់ប៉ុណ្ណោះ"។ អនុលោមតាមវិធាន ១០៨ (៣) និង ១០៩ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូលនឹងបើកសវនាការជាសាធារណៈ ដើម្បីស្តាប់ទឡ្ហីករណ៍ផ្ទាល់មាត់លើបណ្តឹងសាទុក្ខចំពោះសាលក្រម។ ហេតុដូច្នេះ មិនអនុញ្ញាតឱ្យមានការឆ្លើយតបទៅនឹងចម្លើយតបឡើយ។ ការបរិច្ឆេទនៃសវនាការបណ្តឹងសាទុក្ខ នឹងត្រូវជូនដំណឹងទៅភាគីទាំងអស់ក្នុងពេលវេលាសមស្របខាងមុខ។

---

[40] សូមមើល សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អៀង សារី សុំដាក់បណ្តឹងសាទុក្ខ តែជាភាសាអង់គ្លេសសិន ហើយអត្ថបទជាភាសាខ្មែរ នឹងដាក់តាមក្រោយ, ឯកសារ E254/3/1/1.2, ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៣, កថាខណ្ឌ ៤។

២៣. យោងតាមសំអាងហេតុខាងលើ **អង្គជំនុំជម្រះតុលាការកំពូលៈ**

**សម្រេច**ទទួលយកផ្នែកខ្លះនៃសំណើ,

**បង្គាប់**ថា សហព្រះរាជអាជ្ញា ត្រូវដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួនត្រឹមថ្ងៃ សុក្រ ទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ យ៉ាងយូរ គឺរយៈពេល ៦០ ថ្ងៃ គិតចាប់ពីថ្ងៃដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ខ្លួន,

**បង្គាប់**ថា នួន ជា និង ខៀវ សំផន ត្រូវដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួនត្រឹមថ្ងៃ ច័ន្ទ ទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ គឺរយៈពេល ៩០ ថ្ងៃ គិតចាប់ពីថ្ងៃដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ខ្លួន,

**ទទួលយក**សំណើរបស់ នួន ជា និង ខៀវ សំផន សុំដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួនតែមួយភាសា ជាភាសាអង់គ្លេស ឬបារាំង អនុលោមតាមមាត្រា ៧.២ នៃសេចក្តីណែនាំអនុវត្ត ហើយឯកសារជាភាសាខ្មែរ នឹងត្រូវដាក់ជូនតាមក្រោយឱ្យបានឆាប់រហ័សបំផុតតាមដែលអាចធ្វើបាន,

**បង្គាប់**ថា សហព្រះរាជអាជ្ញា ត្រូវដាក់សារណាតបរួមរបស់ខ្លួនក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃដាក់សារណាបណ្តឹងសាទុក្ខចុងក្រោយណាមួយរបស់ នួន ជា និង ខៀវ សំផន ជាភាសាខ្មែរ

**បង្គាប់**ថា សារណាបណ្តឹងសាទុក្ខនីមួយៗរបស់ នួន ជា និង ខៀវ សំផន មិនត្រូវលើសពី ២១០ ទំព័រ ជាភាសាអង់គ្លេស ឬភាសាបារាំង ដោយមិនមានការកម្រិតលើចំនួនទំព័រដែលសមមូលជាភាសាខ្មែរឡើយ, និង

**បង្គាប់**ថា សារណាតបរួមរបស់សហព្រះរាជអាជ្ញា មិនត្រូវលើសពី ២៨០ទំព័រ ជាភាសាអង់គ្លេស ឬភាសាបារាំង ហើយមិនមានការកម្រិតលើចំនួនទំព័រសមមូលជាភាសាខ្មែរឡើយ,

**ប្រកាស**ថា ការឆ្លើយតបណាមួយទៅនឹងសារណាតប ពុំត្រូវបានអនុញ្ញាតឡើយ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០១៤

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រឹម**